

# ឧបសម្ព័ន្ធ "ខ"

# ការបណ្ដុះបណ្ដូលត្រចៀករាងសំបកខ្យង និងការស្ដាប់ឮ

មនុស្សអាចស្ដាប់ឮសម្លេងបានដោយសារបំណែកមួយនៃត្រចៀក ហៅថា "បណ្ដូលត្រចៀករាងសំបកខ្យង" បញ្ជូនសញ្ញាអំពីសម្លេងទៅឱ្យខួរក្បាល ។ បើបណ្ដូលត្រចៀករាងសំបកខ្យងរបស់បុគ្គលម្នាក់បានខូច គាត់នឹងមិនអាចស្ដាប់ឮសម្លេងបានទេ ។

ការវះកាត់ដាក់បណ្ដុះបណ្ដូលត្រចៀករាងសំបកខ្យង គឺជាវិធីថ្មីមួយដើម្បីជួយកុមារថ្លង់ឱ្យស្ដាប់ឮសម្លេង ។ ការវះកាត់បែបនេះមាននៅតាមបណ្ដាប្រទេសជាច្រើន ថ្វីបើវាថ្លៃហួសហេតុក៏ដោយ ។

ដើម្បីផ្ដល់ "បណ្ដូលត្រចៀករាងសំបកខ្យងសិប្បនិម្មិត" ឱ្យអ្នកណាម្នាក់ ឆ្អឹងនៃក្បាលរបស់គាត់ត្រូវតែកាត់ចំហរនៅក្នុងការវះកាត់មួយ ។ បំណែកនៃឧបករណ៏តូចមួយហៅថា " បណ្ដូលត្រចៀកបណ្ដុះរាងសំបកខ្យង" គឺបានស៊កបញ្ចូលក្នុងចំណែកដ៏ជ្រៅបំផុតនៃត្រចៀក ។

**នៅខាងក្នុងត្រចៀក**




**បណ្ដូលត្រចៀករាងសំបកខ្យងគឺជាបំណែកតូចមួយនៅខាងក្នុងក្បាល ។ វាមានរាងវៀដូចសំបកខ្យង ។**

**បំណែកនៃបណ្ដូលត្រចៀកបណ្ដុះរាងសំបកខ្យង**

បំណែកនៃបណ្ដូលត្រចៀកបណ្ដុះរាងសំបកខ្យងខាងក្នុងក្បាល ។ បំណែកផ្សេងទៀតបានពាក់នៅខាងក្រៅក្បាលដូចឧបករណ៏ជំនួយការស្ដាប់អញ្ចឹងដែរ ។



## តើបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងអាចជួយដល់អ្នកណាខ្លះ?

បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង គឺបានផ្តល់ឱ្យតែកុមារថ្លង់ទាំងស្រុង ឬកុមារអាចស្តាប់ឮតិចតួចប៉ុណ្ណោះ ទោះជាកុមារពាក់ឧបករណ៍ជំនួយការស្តាប់ក្តី។ នៅតាមប្រទេសខ្លះ ទារកតូចអាយុ6ខែអាចទទួលបានបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង។ នៅតំបន់ខ្លះទៀត កុមារត្រូវតែមានអាយុចាប់ពី1 ទៅ2ឆ្នាំ។ បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងមិនជួយមនុស្សដែលស្តាប់ឮស្រាប់នោះទេ។

## អនុភាពនៃបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងលើការស្តាប់ឮ

បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងមិនបានព្យាបាលភាពថ្លង់ឡើយ។ មីក្រូបណ្តុះខាងក្រៅក្បាល និងចរន្តដំណើរការបញ្ជូនសញ្ញាទៅឱ្យបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងខាងក្នុងក្បាល ដែលជាអ្នកបន្តបញ្ជូនសញ្ញានោះទៅឱ្យខួរក្បាល។ បំណែកខាងក្រៅក្បាល គឺមានការប្រែប្រួលតែមួយរយៈពេលមានកំណត់ ដើម្បីឱ្យជួបនឹងតម្រូវការរបស់កុមារម្នាក់ៗ។

បើសិនជាកូនអ្នកមិនប្រើបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងឱ្យបានត្រឹមត្រូវ ក្មេងនឹងមិនឮសម្លេងអ្វីមួយឡើយ។ ទោះបីជានៅពេលដែលបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងមានដំណើរការល្អក៏ដោយ សម្លេងដែលបានឮតាមរយៈបណ្តូលត្រចៀកបណ្តុះមានភាពខុសប្លែកពីការស្តាប់ឮធម្មតា។ មនុស្សមួយចំនួននិយាយថា សម្លេងហាក់ដូចជាសំប៉ែត ឬ "តូចល្អិត" ពួកគេបានប្រៀបធៀបវាទៅនឹងការស្តាប់វិទ្យុដែលស្ថានីយ៍ផ្សាយមិនសូវច្បាស់។ កុមារដែលពាក់បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងនឹងត្រូវចំណាយពេលមួយរយៈកាល និងការអនុវត្តដើម្បីរៀនយល់សម្លេងដែលពួកគេបានឮ។ កុមារត្រូវតែទៅថ្នាក់រៀនដើម្បីបណ្តុះបណ្តាលក្នុងវិធី "ស្តាប់ឮ" ជាមួយនឹងបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង។

**កុមារីនេះអាចឮសម្លេងនិយាយរបស់ក្រុមគ្រួសារនាង។ នាងត្រូវតែរៀនភាពខុសគ្នារវាងសម្លេងនៃបុគ្គលម្នាក់ៗ។**




លទ្ធផលនៃការវះកាត់ ឧបករណ៍ និងថ្នាក់បណ្តុះបណ្តាល គឺវាខុសៗគ្នាសំរាប់កុមារម្នាក់ៗ។ កុមារមួយចំនួនធំដែលបានពាក់បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង ត្រូវខិតខំយ៉ាងខ្លាំងនៅអំឡុងពេលបណ្តុះបណ្តាលនឹងអាចស្តាប់ឮហើយយល់ពីសម្លេង។ កុមារមួយចំនួនដែលបានពាក់បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង នឹងរៀនចេះនិយាយផងដែរ។ ក្មេងឯទៀតអាចរៀនរបៀបស្តាប់ឮសម្លេង និងនិយាយ ប៉ុន្តែមិនសូវច្បាស់ល្អទេ។

## តើបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង គឺជាជំរើសល្អចំពោះគ្រួសារអ្នកឬទេ?

បើសិនជាអ្នកព្យាយាមសំរេចចិត្តថា តើបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង គឺជាជំរើសសមស្របសំរាប់កូនអ្នក នេះគឺជាអ្វីៗដែលត្រូវគិតពិចារណា។

## តើបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង និងការគាំទ្រផ្នែកឯកទេសមាននៅក្នុងតំបន់របស់អ្នកដែរឬទេ?

នៅបណ្តាប្រទេសជាច្រើនមិនមានវេជ្ជបណ្ឌិត ឬមនុស្សមានជំនាញឯកទេសដើម្បីធ្វើការជាមួយការបណ្តុះបណ្តូលត្រចៀករាងសំបកខ្យង។ នៅបណ្តាប្រទេសស្ទើរតែទាំងអស់មានវេជ្ជបណ្ឌិតដែលធ្វើការវះកាត់ តែជាធម្មតាពួកគេមាននៅតាមមន្ទីរពេទ្យធំៗក្នុងទីក្រុង កន្លែងដែលប្រហែលជាមានមណ្ឌលសំរាប់បណ្តុះបណ្តូលត្រចៀករាងសំបកខ្យង។

ការមានមណ្ឌលសំរាប់បណ្តុះបណ្តូលត្រចៀករាងសំបកខ្យងនៅជិតអ្នក គឺជាការសំខាន់។ អ្នកនិងកូនត្រូវទៅកាន់មណ្ឌលនេះជាច្រើនលើកក្នុងរយៈពេលពីរបីឆ្នាំ។ ក្រសួងសុខាភិបាលនៅប្រទេសអ្នក ឬសាលារៀនសំរាប់កុមារថ្លង់ប្រហែលជាអាចប្រាប់អ្នក បើសិនជាមានមណ្ឌលសំរាប់បណ្តុះបណ្តូលត្រចៀករាងសំបកខ្យងដែលនៅជិតអ្នក។

## ការចំណាយក្នុងការវះកាត់ និងដាក់បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង

ការវះកាត់ ឧបករណ៍ និងតម្លៃនៃការបណ្តុះបណ្តាលរាប់ឆ្នាំជាមួយអ្នកឯកទេស គឺថ្លៃខ្លាំងណាស់។ នៅប្រទេសឥណ្ឌា ការបណ្តុះបណ្តូលត្រចៀករាងសំបកខ្យងអាចមានតម្លៃ 10,000ដុល្លារសហរដ្ឋអាមេរិក។ (ឧបករណ៍ជំនួយការស្តាប់មានតម្លៃ 75ដុល្លារសហរដ្ឋអាមេរិក)។ ករណីឧបករណ៍ជំនួយការស្តាប់ កុមារអាចធ្វើបាត់ ឬធ្វើបែកបំណែកណាមួយដែលពាក់នៅខាងក្រៅក្បាល។ បំណែកទាំងនេះអាចថ្លៃខ្លាំងណាស់ដើម្បីដូរថ្មី។

**នៅប្រទេសចិន តម្លៃក្នុងការវះកាត់ ឧបករណ៍ និងការបណ្តុះបណ្តាល ស្មើនឹងប្រាក់ខែមធ្យមភាគ ចំនួន 20ឆ្នាំនៃកម្មករម្នាក់។**

**នៅប្រទេសម៉ិចស៊ិក តម្លៃនៃការបណ្តុះបណ្តូលត្រចៀករាងសំបកខ្យង ស្មើនឹងប្រាក់ខែចំនួន 4ឆ្នាំនៃវេជ្ជបណ្ឌិតម្នាក់។**





បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងដែលថោក និងចាស់មិនមានប្រសិទ្ធភាពល្អដូចឧបករណ៍ដែលថ្លៃ និងថ្មីនោះទេ។ នៅប្រទេសខ្លះមានកម្មវិធីផ្តល់បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យងដោយឥតគិតថ្លៃ ឬយកតម្លៃថោក។



បណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង គឺដូចជាប្រភេទគាំពារសុខភាពឯទៀតដែរ មិនគួរត្រូវបានផ្តល់ឱ្យចំពោះអ្នកមានលុយគ្រប់គ្រាន់ដែលមានលទ្ធភាពទិញពួកវានោះទេ។ បើសិនជាបណ្តូលត្រចៀកបណ្តុះរាងសំបកខ្យង គឺជាករណីល្អបំផុតសំរាប់កុមារម្នាក់ នោះការវះកាត់ និងគាំទ្រគួរត្រូវបានផ្តល់ឱ្យកុមារ។

**បណ្តូលត្រចៀកបណ្តុះវាងសំបកខ្យង និងជំងឺ**

ពេលខ្លះបណ្តូលត្រចៀកបណ្តុះវាងសំបកខ្យង អាចបង្កឱ្យមានការរលាកដែលធ្វើឱ្យការស្តាប់ឮកាន់តែដុនដាប ។ ចំពោះកុមារពាក់បណ្តូលត្រចៀកបណ្តុះវាងសំបកខ្យង ការព្យាបាលជំងឺត្រចៀកឱ្យបានឆាប់រហ័ស គឺជាការសំខាន់ ។ វាក៏សំខាន់ផងដែរក្នុងការវ៉ាក់សាំងកុមារដើម្បីទប់ស្កាត់ជំងឺតែងកើតនៅអំឡុងកុមារភាព ។

ឧបករណ៍បណ្តូលត្រចៀកបណ្តុះវាងសំបកខ្យង និងការវះកាត់ក៏អាចបណ្តាលឱ្យកើតជំងឺដ៏ធ្ងន់ធ្ងរហៅថារលាកស្រោមខួរផងដែរ ទោះជាច្រើនឆ្នាំទៅមុខទៀតក៏ដោយ ។ ជំងឺរលាកស្រោមខួរ គឺជាជំងឺឆ្លងដ៏ធ្ងន់ធ្ងរនៃខួរក្បាល និងអាចកើតឡើងចំពោះកុមារដែល :-



- មានវ័យតិចជាង 5ឆ្នាំ ។
- ក្លាយជាថ្លង់ដោយសារតែរលាកស្រោមខួរ ។
- កើតជំងឺត្រចៀក ។
- ឈឺញឹកញាប់ ។

សំរាប់ព័ត៌មានបន្ថែមអំពីជំងឺរលាកស្រោមខួរ សូមអានទំព័រ201 ក៏ដូចជាអានសៀវភៅ **ទីណាដែលគ្មានវេជ្ជបណ្ឌិត** បានបោះពុម្ពដោយមូលនិធិហេសស្តើរៀន ហើយក៏មានជាភាសាខ្មែរ និងអាចរកជាវបានតាមទីផ្សារក្នុងប្រទេសកម្ពុជា ។

## ការថែទាំ និងគាំទ្រក្រោយពេលវះកាត់




កុមារតូចដែលពាក់បណ្តូលត្រចៀកបណ្តុះវាងសំបកខ្យង ត្រូវការជួយជ្រោមជ្រែងបន្ថែមពីក្រុមគ្រួសារ និងអ្នកឯកទេស ។ ក្រោយពេលកុមារជាសះស្បើយពីការវះកាត់ ពួកគេត្រូវតែចំណាយពេលរាប់ឆ្នាំ ដើម្បីរៀនអំពីការស្តាប់និងយល់សម្លេង ដែលពួកគេស្តាប់ឮ ។ ក្រុមគ្រួសារក៏ត្រូវការបណ្តុះបណ្តាលអំពីរបៀបប្រាស្រ័យទាក់ទងជាមួយកុមារផងដែរ ។